# Living the Lotus

**8**
**2023**
**VOL. 215**

*Buddhism in Everyday Life*





**Living the Lotus**
**Vol. 215 (August 2023)**

Senior Editor: Keiichi Akagawa
Editor: Sachi Mikawa
Copy Editor: Penn Setharin
*Living the Lotus* is published monthly by Rissho Kosei-kai International, Fumon Media Center, 2-7-1 Wada, Suginami-ku, Tokyo 166-8537, Japan.
TEL: +81-3-5341-1124
FAX: +81-3-5341-1224
Email: living.the.lotus.rk-international@kosei-kai.or.jp


រីហ្សូក្ខូសេកៃគឺជាអង្គការចលនាពុទ្ធសាសនាសកលមួយដែលមានពុទ្ធបរិស័ទ ជាច្រើនមានជំនឿលើគម្ពីព្រះសូត្រផ្កាឈូកសដែលជាព្រះសូត្ររបស់ព្រះពុទ្ធសាសនាមួយដ៏សំខាន់។ ពុទ្ធបរិស័ទទាំងនោះ បានខិតខំអនុវត្តការបង្រៀន របស់ព្រះបរមគ្រូនៃយើងទៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃដូចជា នៅកន្លែងការ ងារឬនៅក្នុងក្រុមគ្រួសាររបស់ពួកគាត់ជាដើម។ជាពិសេសគឺខំប្រឹងអនុវត្តធ្វើយ៉ាងណាអោយពិភពលោកទទួលបានសុខសន្តិភាព។

អង្គការរីហ្សូក្ខូសេកៃ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1983 ដោយ ស្ថាបនិក Nikkyo Niwano (1906-1999) និង, សហស្ថាបនាយិកា Myoko Naganuma (1889-1957) បច្ចុប្បន្នក្រោមការណែនាំពីលោកប្រធាន Nichiko Niwano សមាជិក រីហ្សូក្ខូ សេកៃទាំងអស់ក្នុងនាមជាពុទ្ធបរិស័ទបានកំពុងប្រឹងប្រែងយ៉ាងសកម្មក្នុងការចែករំលែកព្រះធម៌និងចូលរួមសកម្មភាពសន្តិភាពទាំងក្នុងនិងក្រៅប្រទេសក្នុងកិច្ចសហការជាមួយមនុស្សគ្រប់មជ្ឈដ្ឋាន។

The title of this newsletter, *Living the Lotus—Buddhism in Everyday Life*, conveys our hope of striving to practice the teachings of the Lotus Sutra in daily life in an imperfect world to enrich and make our lives more worthwhile, like beautiful lotus flowers blooming in a muddy pond. This newsletter aims to help people around the world apply Buddhism more easily in their daily lives.

# ដើម្បីឱ្យអាចរស់បានប្រកបដោយភាពកក់ក្ដៅ

ព្រះគ្រូនីវ៉ាណុ នីជិកុ
ព្រះប្រធានរីហ្សូកូសេកៃ



## ត្រូវធ្វើយ៉ាងណាដើម្បីកុំឱ្យប្រទេសទាំងអស់រលត់រលាយ

ស្ថាប័នអនាម័យពិភពលោកបានផ្ដល់និយមន័យទៅលើពាក្យសុខភាពល្អថា៖គឺមិនមែនជាស្ថានភាពដែលគ្មានជម្ងឺ ឬចុះទន់ខ្សោយទេ គឺស្ថានភាពដែលត្រូវបានបំពេញឱ្យបានពេញលេញទាំងផ្នែករាងកាយ ទាំងផ្នែកស្មារតី និងទាំងផ្នែកសង្គម។និយមន័យនេះវាដូចគ្នានឹងនិយមន័យនៃពាក្យថាមានសុភមង្គលដែរ។

ក៏ប៉ុន្តែបើមើលទៅត្រឹមតែទង្វើឈ្លានពានរបស់រុស្ស៊ីទៅលើអ៊ុយក្រែនឬក៏សង្គ្រាមស៊ីវិលដែលនៅតែបន្តនៅស៊ីរី ស៊ូដង់ ភូមា ។ល។និង។ល។, អត្តិភាពនៃអ្នកភៀសខ្លួននៅតំបន់នានា, បញ្ហាសិទ្ធិមនុស្ស និងបញ្ហានានារបស់ជប៉ុនជាមួយនឹងបណ្ដាប្រទេសជិតខាង យើងសឹងតែអាចនិយាយបានថាគ្មានមនុស្សដែលរស់នៅដោយសុខភាពល្អនិងមានសុភមង្គលទេនៅក្នុងស្ថានភាពបច្ចុប្បន្ននៃពិភពលោកសព្វថ្ងៃនេះ ។សភាពពិតនៃនយោបាយពិភពលោកសព្វថ្ងៃនេះគ្រប់គ្រងដោយកម្លាំងយោធា បណ្ដាប្រទេសទាំងឡាយខិតខំបង្កើនកម្លាំងទ័ពឱ្យបានបរិបូរណ៍ ហើយឃ្លាំមើលព្រមទាំងដាក់គំនៀបទៅលើដៃគូដើម្បីគ្រប់គ្រងទង្វើគ្នាទៅវិញទៅមក។ ដោយសារតែទង្វើនេះគេក៏អាចបង្ក្រាបកុំឱ្យមានការប៉ះទង្គិចអាវុធគ្នាទៅវិញទៅមកបានតែប៉ុណ្ណោះ ដូច្នេះទោះបីជាថាប្រទេសខ្លះឬក៏តំបន់ខ្លះមើលនឹងភ្នែកទៅឃើញហាក់ដូចជាមានសន្តិភាពក្ដី ក៏យើងអាចនិយាយបានថាប្រទេសឬតំបន់ទាំងនោះស្ថិតនៅក្រោមភាពតានតឹងបែបយោធាដែរ។

គ្រាន់តែថា ករណីយ៍ទាំងនេះមិនមែនទើបតែមានឡើងក្នុងបច្ចុប្បន្នកាលនេះទេ ។នៅឆ្នាំ១៩៨២ស្ថាបនិកកៃស្ញូសាម៉ា លោកបានសរសេរថា៖ស្ថានភាពបច្ចុប្បន្ននៃពិភពលោកសព្វថ្ងៃនេះស្ថិតនៅក្នុងភាពតានតឹងណាស់  គេមិនដឹងថាតើសង្គ្រាមលោកលើកទី៣នឹងផ្ទុះឡើងនៅពេលណាទេ។

“ការត្រៀមនិងបង្កើនកម្លាំងសព្វាវុធទាំងឡាយមានមូលហេតុមកពីការបារម្ភខ្លាចមានការឈ្លានពានពីប្រទេសដទៃនោះឯង។”ហើយលោកបានលើកទឹកចិត្តចលនាប្រមូលហត្ថលេខាឱ្យ

បញ្ឈប់ជាដាច់ខាតនូវការប្រើអាវុធបរមាណូនិងការបន្តយកម្លាំងយោធាដែលប្រព្រឹត្តទៅនាពេលនោះថាជាចលនាដ៏មានន័យណាស់។

នរណាក៏ដូចនរណា ទោះបីជាគ្រាន់តែគិតក៏បារម្ភបាត់ទៅហើយ ខ្លាចតែប្រទេសខ្លួនឯងរលត់រលាយដោយការចូលឈ្លានពានពីប្រទេសដទៃ។លើសពីនេះទៅទៀតដោយសារតែការការពារប្រទេស គឺជាការពារជីវិតខ្លួន និងការពារគ្រួសាររបស់ខ្លួនស្ថិតនៅលើបន្ទាត់បន្តនៃមនោសញ្ចេតនាដូច្នេះយើងអាចនិយាយបានថាការពឹងពាក់ទៅលើសព្វាវុធគឺជាអភន្តរញ្ញាណរបស់មនុស្ស។ក៏ប៉ុន្តែការបារម្ភពីការឈ្លានពានពីសំណាក់បរទេស ការជេរប្រទេចឬមានចិត្តជាសត្រូវមិនមែនជាចិត្តប្រកបទៅដោយសុខភាពល្អប្រសើរទេ។ក្នុងន័យនេះដើម្បីឱ្យយើងទាំងអស់គ្នាអាចរស់នៅបានដោយសុខភាពល្អនិងសុភមង្គលបាន យើងត្រូវរកវិធីការពារប្រទេសជាតិដោយមិនរំពឹងទៅលើការពង្រឹងផ្នែកយោធាទេពោលគឺថាធ្វើយ៉ាងណាកុំឱ្យប្រទេសទាំងឡាយរលុបបាត់ពីផែនទីពិភពលោក។

## ស្រឡាញ់គេឱ្យដូចស្រឡាញ់ខ្លួនឯង

មានកំណាព្យមួយចែងថា ឱថ្ងៃទី៦ ទី៩និងទី១៥ នៃខែសីហា!

គឺកំណាព្យដែលថ្លែងពីសោកនាដកម្មនិងភាពអមនុស្សធម៌នៃការទម្លាក់គ្រាប់បែកបរមាណូជាថ្ងៃចាញ់សង្គ្រាមនៃប្រទេសជប៉ុន,ការសោកស្តាយ សោកសង្រេង, ការឧទ្ទិសកុសលនិងលួងលោមព្រលឹងអ្នកដែលបានទទួលមរណភាពនៅក្នុងសោកនាដកម្មនោះ។ទោះបីជា៧៨ឆ្នាំបានកន្លងហួសទៅហើយក្តី ក៏អានទៅពេលណាក៏នាំឱ្យទ្រូងឈឺផ្សា។ដោយសារតែមានសោកនាដកម្មនេះហើយទើបបានជាអាត្មាភាពបួងសួងសុំឱ្យពិភពលោកមានភាពកក់ក្តៅសម្រាប់មនុស្សទាំងអស់ដែលរស់នៅលើលោកនេះ។

ស្ថាបនិកកៃសូសាម៉ាលោកតែងតែគិតថា៖សង្គ្រាមនិងវិវាតកើតឡើងដោយសារអស្មិមានះនិងការរើសអើងព្រមទាំងសេចក្តីស្អប់សេចក្តីច្រណែន។ប្រសិនបើយើងមិនទប់អារម្មណ៍ដ៏អាក្រក់នេះឬក៏មិនធ្វើឱ្យអារម្មណ៍បែបនេះចុះថយទេ វិវាតមិនអាចរលុបបាត់ពីពិភពមនុស្សលោកបានទេ ហើយលោកបានបញ្ជាក់ថាមានតែសាសនាទេដែលអាចតម្រែតម្រង់ចិត្តរបស់មនុស្សឱ្យទៅជាល្អបាន។សាសនាគឺជាមហាមាគ៌ាដែលនាំឆ្ពោះទៅរកសន្តិភាព។នៅក្នុងព្រះពុទ្ធសាសនាមានមេត្តា ករុណា រីឯសាសនាគ្រឹស្តវិញមាន ស្នេហា។សាសនាដទៃទៀតក៏ប្រហែលជាមានទ្រឹស្តីប្រហាក់ប្រហែលនឹងគ្នានេះដែរ។យោងទៅតាមការបង្រៀនដែលនាំទៅរកភាពសុខដុំរមនា មនុស្សម្នាក់ៗតោងតែស្រឡាញ់ជីវិតខ្លួន ហើយដូចដែលខ្លួនស្រឡាញ់ជីវិតខ្លួនដែរត្រូវស្រឡាញ់ហើយគោរពអ្នកដទៃ ។ការកសាងឱ្យមានជាពិភពលោកបែបនេះគឺជាបេសក កម្មរបស់អ្នកកាន់សាសនា។ដូច្នេះហើយទើបបានជាកិច្ចប្រជុំសន្តិភាពនៃអ្នកសាសនាពិភពលោកបានចាប់កំណើតឡើងដើម្បីឱ្យអាចសាមគ្គីរួមកម្លាំងគ្នាជាធ្លុងមួយហើយដើរឆ្ពោះទៅរកគោលដៅនោះ។

នៅក្នុងការពិតចំពោះយើងដែលជាបុថុជ្ជនការទប់ស្កាត់កុំឱ្យមានសង្គ្រាមជាការលំបាកណាស់។ក៏ប៉ុន្តែបើមានជំនឿទៅលើសាសនាយើងក៏អាចធ្វើឱ្យចិត្តយើងបានល្អ ហើយអាចមានប្រយោជន៍ចំពោះការធ្វើឱ្យសង្គមនិងប្រទេសជាតិធ្វើដំណើរទៅរកផ្លូវល្អ។ មើលទៅខ្លួនឯងនិងអ្នកដទៃដោយក្រសែភ្នែកមេត្តាករុណា ហើយពង្រីកចក្ខុវិស័យឱ្យកាន់តែទូលាយពីបុគ្គលទៅរកសហគមន៍ ហើយបន្តទៅរកសង្គម រួចហើយទៅរកប្រទេសជាតិ ផ្សព្វផ្សាយប្រាប់ទៅអ្នកទាំងអស់គ្នាថាអ្នកនិងខ្លួនខ្ញុំជាអត្ថិភាពដ៏មានតម្លៃជាមនុស្សដូចគ្នាតែមួយ។ទោះមានសាសនាក្តីមិនមានក្តី តោងតែស្រឡាញ់ជនរួមជាតិជាការធម្មតាព្រមទាំងមនុស្សទាំងឡាយក្នុងសាកលលោក មានសមានចិត្តចំពោះមនុស្ស ឱ្យមានគ្នីគ្នាមិត្តភក្តិច្រើន បន្តផ្ជាប់ទៅនឹងពិភពលោកដែលនរណាម្នាក់ក៏អាចរស់នៅក្នុងភាពកក់ក្តៅ។

ដកស្រង់ពី “ទស្សនាវត្តីកូសេ” លេខ៨ ឆ្នាំ២០២៣




# A Global Buddhist Movement




Information about local Dharma centers

facebook

twitter

We welcome comments on our newsletter Living the Lotus: living.the.lotus.rk-international@kosei-kai.or.jp